## ៨-២-៤ បុណ្យចេញវស្សា

*បុណ្យចេញវស្សា ជាបុណ្យរបស់ព្រះសង្ឃ ដែលបានចូលវស្សាគ្រប់ចំនួន៣ខែ ហើយ។ បុណ្យនេះប្រារព្ធឡើងនៅថ្ងៃ ១៥កើត ខែអស្សុជ(ខែតុលា-វិច្ឆិកា)។*

*តាមទំនៀម នៅពេលបុណ្យចេញវស្សា អ្នកស្រុកគេយកសំពត់ស្បង់ ឬអ្វីមួយ ទៅប្រគេនព្រះសង្ឃ ទុកជាទីរលឹកមុននឹងលោកចេញដំណើរទៅកាន់ទីផ្សេងៗទៀត។ តែឥឡូវនេះអ្នកស្រុកពុំសូវធ្វើទេ ព្រោះបុណ្យនេះ ជាប់នឹងបុណ្យកឋិន។ ម្យ៉ាងទៀតតាមគម្ពីរតំណាលថានៅសម័យពុទ្ធកាលក្នុងវស្សាទី៧ ព្រះពុទ្ធអង្គបានយាងទៅកាន់ស្ថានតាវត្តឹង្ស ដើម្បីប្រោស ព្រះមាតា ហើយនៅថ្ងៃចេញវស្សានោះទើបព្រះអង្គលោកយាងវិលត្រឡប់មកវិញតាមជណ្ដើរកែវនៅត្រង់"សង្កស្សនគរ" នៃប្រទេសឥណ្ឌាសព្វថ្ងៃនេះ។ ហើយនៅពេលនោះព្រះអង្គបានធ្វើ យមកបាដិហារិយ៍បើកលោកឲ្យពពួកទេវតានិងមនុស្សទាំងឡាយ មើលឃើញគ្នា ទៅវិញ ទៅមក ។*

*<u>សេចក្ដីសន្និដ្ឋាន</u>: បើអាចធ្វើបាន គួរតែបបួលគ្នាមកវត្តឲ្យបានច្រើន ដើម្បីធ្វើបុណ្យធ្វើទាន នៅថ្ងៃចេញវស្សានេះ ។*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*